ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# សេចក្ដីណែនាំ

ដល់បេក្ខជនក្នុងពេលប្រឡងប្រជែងជ្រើសរើសមន្ត្រីសុខាភិបាលឱ្យចូលបម្រើការងារនៅ

## មន្ទីរពេទ្យបង្អែកកម្រិត១ ប៊ុនរ៉ានី ហ៊ុនសែន រុនតាឯក
## និង មន្ទីរពេទ្យបង្អែកកម្រិត១ ពាក់ស្នែង

គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤៣៦៤/២៤ មស.គណមេ

## សេចក្តីណែនាំ
## ដល់បេក្ខជនក្នុងពេលប្រឡង

បេក្ខជនចូលរួមការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារនៅមន្ទីរពេទ្យបង្អែកកម្រិត១ ប៊ុនរ៉ានី ហ៊ុនសែន រុនតាឯក នៃរដ្ឋបាលខេត្តសៀមរាប សម័យប្រឡងថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងសាលាភូមិន្ទរដ្ឋបាល ត្រូវគោរព និងអនុវត្តតាមការណែនាំដូចតទៅ៖

- ត្រូវចូលមកមណ្ឌលប្រឡង ដោយយកភ្ជាប់ជាមួយនូវសលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងប៊ិកខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។
- ហាមយកជាប់ជាមួយនូវឯកសារ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ ទូរស័ព្ទ នាឡិកាឆ្លាតវៃ...)។ គណៈកម្មការរៀបចំការប្រឡងប្រជែងមិនទទួលខុសត្រូវរក្សាទុកនូវឯកសារ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ។
- ករណីមកយឺតម៉ោង "តិចជាង ១៥នាទី" បន្ទាប់ពីការចាប់ផ្តើមវិញ្ញាសា ត្រូវសុំការអនុញ្ញាតពីប្រធានមណ្ឌលប្រឡងជាមុន ទើបអាចចូលប្រឡងបាន និងប្រគល់សន្លឹកកិច្ចការប្រឡងតាមម៉ោងកំណត់។ ការមកយឺតយ៉ាវ "លើស ១៥នាទី" បន្ទាប់ពីការចាប់ផ្តើមវិញ្ញាសា មិនអនុញ្ញាតឱ្យចូលប្រឡងដាច់ខាត។
- អវត្តមានមិនបានប្រឡងវិញ្ញាសាណាមួយ នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងវិញ្ញាសាបន្តបន្ទាប់ឡើយ។
- មិនត្រូវចូលបន្ទប់ប្រឡងមុនពេលហៅឈ្មោះ ត្រូវអង្គុយតាមលេខតុដែលបង្ហាញ ត្រូវសរសេរឈ្មោះ និងលេខតុលើក្បាលសន្លឹកកិច្ចការប្រឡងតាមការណែនាំរបស់អនុរក្ស និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញ ទោះបីជាក្រដាសប្រឡងគ្មានសរសេរចម្លើយ ឬដំណោះស្រាយអ្វីក៏ដោយ។ ការមិនប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្ស ចាត់ទុកអវត្តមាន។
- មិនត្រូវសរសេរក្នុងសញ្ញាខ្វែងនៃគ្រប់ទំព័រសន្លឹកកិច្ចការប្រឡង និងមិនត្រូវធ្វើគំនូសសញ្ញាធ្វើឱ្យដឹងអាគតដ្ឋាននៃសន្លឹកកិច្ចការប្រឡងឡើយ។
- មិនត្រូវធ្វើសកម្មភាពលួចចម្លងតាមគ្រប់រូបភាព ប៉ុនប៉ងលួចចម្លង ឬ ចែករំលែកព័ត៌មានដល់អ្នកដទៃ។
- បេក្ខជនត្រូវដឹងអំពីសញ្ញាជួង៖
    - +ជួងទី១៖ ចូលបន្ទប់ប្រឡងបំពេញក្បាលសន្លឹកកិច្ចការប្រឡង
    - +ជួងទី២៖ ចាប់ផ្តើមធ្វើវិញ្ញាសា
    - +ជួងទី៣៖ រំឭកថានៅសល់ ១៥នាទីទៀត ដល់ម៉ោងត្រូវប្រមូលសន្លឹកកិច្ចការប្រឡង
    - +ជួងទី៤៖ ប្រគល់សន្លឹកកិច្ចការប្រឡងឱ្យអនុរក្សជាកំហិត។

បេក្ខជនដែលមិនគោរពប្រតិបត្តិតាមការណែនាំខាងលើ ឬគំរាមកំហែង ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយស បូរណភាពរូបរាងកាយមន្ត្រីមានសមត្ថកិច្ចទាំងក្នុងបន្ទប់ប្រឡង និងក្រៅបន្ទប់ប្រឡង នឹងត្រូវបញ្ឈប់មិនឱ្យប្រឡងជាបន្ទាន់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តនេះ និងហាមឃាត់មិនឱ្យចូលរួមប្រឡងប្រជែងក្នុងការជ្រើសរើសមន្ត្រីរាជការ ព្រមទាំងទទួលខុសត្រូវតាមវិធានច្បាប់ជាធរមាន។

គណៈមេប្រយោគ មានជំនឿយ៉ាងមុតមាំចំពោះស្មារតីទទួលខុសត្រូវ និងចូលរួមថែរក្សាឱ្យបាននូវភាពរលូននៃដំណើរការប្រឡងរបស់បេក្ខជន។

ថ្ងៃ ពុធ ៣រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២៤
**ប្រធានគណៈមេប្រយោគ**

ហ៊ុន_ម៉ានី

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៤៣៦៦/២៤ មស.គសរ

## សេចក្តីណែនាំ
## ដល់បេក្ខជនក្នុងពេលប្រឡង

បេក្ខជនចូលរួមការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារនៅមន្ទីរពេទ្យបង្អែកកម្រិត១ ពាក់ស្នែង នៃរដ្ឋបាលខេត្តសៀមរាប សម័យប្រឡងថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២៤ នៅមណ្ឌលប្រឡងសាលាភូមិន្ទរដ្ឋបាល ត្រូវគោរព និងអនុវត្តតាមការណែនាំដូចតទៅ៖

- ត្រូវចូលមកមណ្ឌលប្រឡង ដោយយកភ្ជាប់ជាមួយនូវសលាកបត្រឯកត្តជន និងអត្តសញ្ញាណប័ណ្ណ ឬឆាយា(ព្រះសង្ឃ) ឬលិខិតបញ្ជាក់អត្តសញ្ញាណផ្សេងទៀតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងប៊ិកខៀវ និងបន្ទាត់ សម្រាប់ប្រើប្រាស់ពេលប្រឡង។
- ហាមយកជាប់ជាមួយនូវឯកសារ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ (កុំព្យូទ័រ ទូរស័ព្ទ នាឡិកាឆ្លាតវៃ...)។ គណៈកម្មការរៀបចំការប្រឡងប្រជែងមិនទទួលខុសត្រូវរក្សាទុកនូវឯកសារ និងឧបករណ៍អេឡិចត្រូនិកគ្រប់ប្រភេទ។
- ករណីមកយឺតម៉ោង "តិចជាង ១៥នាទី" បន្ទាប់ពីការចាប់ផ្តើមវិញ្ញាសា ត្រូវសុំការអនុញ្ញាតពីប្រធានមណ្ឌលប្រឡងជាមុនទើបអាចចូលប្រឡងបាន និងប្រគល់សន្លឹកកិច្ចការប្រឡងតាមម៉ោងកំណត់។ ការមកយឺតយ៉ាវ "លើស ១៥នាទី" បន្ទាប់ពីការចាប់ផ្តើមវិញ្ញាសា មិនអនុញ្ញាតឱ្យចូលប្រឡងដាច់ខាត។
- អវត្តមានមិនបានប្រឡងវិញ្ញាសាណាមួយ នឹងមិនត្រូវបានអនុញ្ញាតឱ្យប្រឡងវិញ្ញាសាបន្តបន្ទាប់ឡើយ។
- មិនត្រូវចូលបន្ទប់ប្រឡងមុនពេលហៅឈ្មោះ ត្រូវអង្គុយតាមលេខតុដែលបង្ហាញ ត្រូវសរសេរឈ្មោះ និងលេខតុលើក្បាលសន្លឹកកិច្ចការប្រឡងតាមការណែនាំរបស់អនុរក្ស និងប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្សវិញ ទោះបីជាក្រដាសប្រឡងគ្មានសរសេរចម្លើយ ឬដំណោះស្រាយអ្វីក៏ដោយ។ ការមិនប្រគល់សន្លឹកកិច្ចការប្រឡងដល់អនុរក្ស ចាត់ទុកអវត្តមាន។
- មិនត្រូវសរសេរក្នុងសញ្ញាខ្វែងនៃគ្រប់ទំព័រសន្លឹកកិច្ចការប្រឡង និងមិនត្រូវធ្វើគំនូសសញ្ញាធ្វើឱ្យដឹងអាគតដ្ឋាននៃសន្លឹកកិច្ចការប្រឡងឡើយ។
- មិនត្រូវធ្វើសកម្មភាពលួចចម្លងតាមគ្រប់រូបភាព ប៉ុនប៉ងលួចចម្លង ឬ ចែករំលែកព័ត៌មានដល់អ្នកដទៃ។
- បេក្ខជនត្រូវដឹងអំពីសញ្ញាជួង៖
  - +ជួងទី១៖ ចូលបន្ទប់ប្រឡងបំពេញក្បាលសន្លឹកកិច្ចការប្រឡង
  - +ជួងទី២៖ ចាប់ផ្តើមធ្វើវិញ្ញាសា
  - +ជួងទី៣៖ រំឭកថានៅសល់ ១៥នាទីទៀត ដល់ម៉ោងត្រូវប្រមូលសន្លឹកកិច្ចការប្រឡង
  - +ជួងទី៤៖ ប្រគល់សន្លឹកកិច្ចការប្រឡងឱ្យអនុរក្សជាកំហិត។

បេក្ខជនដែលមិនគោរពប្រតិបត្តិតាមការណែនាំខាងលើ ឬគំរាមកំហែង ឬធ្វើឱ្យប៉ះពាល់ដល់កិត្តិយស បូរណភាពរូបរាងកាយមន្ត្រីមានសមត្ថកិច្ចទាំងក្នុងបន្ទប់ប្រឡង និងក្រៅបន្ទប់ប្រឡង នឹងត្រូវបញ្ឈប់មិនឱ្យប្រឡងជាបន្ទាន់ក្នុងសម័យប្រឡងដែលកំពុងប្រព្រឹត្តនេះ និងហាមឃាត់មិនឱ្យចូលរួមប្រឡងប្រជែងក្នុងការជ្រើសរើសមន្ត្រីរាជការ ព្រមទាំងទទួលខុសត្រូវតាមវិធានច្បាប់ជាធរមាន។

គណៈមេប្រយោគ មានជំនឿយ៉ាងមុតមាំចំពោះស្មារតីទទួលខុសត្រូវ និងចូលរួមថែរក្សាឱ្យបាននូវភាពរលូននៃដំណើរការប្រឡងរបស់បេក្ខជន។

ថ្ងៃ ៣រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០២៤
**ប្រធានគណៈមេប្រយោគ**

**ហ៊ុន_ម៉ានី**